ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សភាផ្នែកព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៨

ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨

សាលដីកា

លេខ : ១១

ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១-ឯកឧត្តម ឌិត មុន្ទី ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក សោម សិរីវឌ្ឍ ចៅក្រម

៤- លោក ប្រាក់ គឹមសាន ចៅក្រម

៥- លោក យស់ សូខឿន ចៅក្រមរាជការណ៍

ក្រឡាបញ្ជី

លោក ទោង ចាន់ថា

តំណាងមហាអយ្យការ

លោក រ៉ែប៉ិន សារឿន ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៣៧៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ១១៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

ពីបទ : ធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៤ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣២ នៃច្បាប់-ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

១-ជនជាប់ចោទឈ្មោះអ៊ាង សារឿន " ជាម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាញ៉ៅ ឃុំរការ៥ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម របររកស៊ីលក់ថែ យន្ត ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះលេខ១៦អា ក្រុមទី១៧ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ

ឪពុកឈ្មោះយឹង គឹមអ៊ាង "រ" ម្តាយឈ្មោះពន ថុល "រ" ។ ក្នុងឃុំ ។

មានមេធាវីអ្នកស្រី ជឹម ស៊ីម៉ែន

២_ជនជាប់ចោទឈ្មោះអ៊ាង សុវណ្ណ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាញ៉ែវ ឃុំរកា៥ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម របររកស៊ីរត់ម៉ូតូឌុប ទីលំនៅមុនថ្ងៃគេចខ្លួន ផ្ទះលេខ១២បេ ក្រុម១៧ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះយឹង គឹមអ៊ាង "រ" ម្តាយឈ្មោះពន ថុល "រ" ប្រពន្ធឈ្មោះកែវ សុខលីន មានកូន០២នាក់ ។ គេចខ្លួន ។

-ដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រីមាស សារឿន "ជាចុងបណ្តឹងសាទុក្ខ" អាយុ៣៣ឆ្នាំ ជាតិខ្មែរ របរស៊ីនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៥អា ផ្លូវលេខ៣៤៤ ក្រុមទី១៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

មេធាវី គ្មាន

-តាមបណ្តឹងសាទុក្ខលេខ៤៥៩ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧របស់ឈ្មោះអ៊ាង-សារឿន ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៧៣ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

-តាមពាក្យបណ្តឹងចុះថ្ងៃទី១៦_១២_១៩៩៤ និង ចុះថ្ងៃទី១៧_១២_១៩៩៤ របស់ដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រីមាស សារឿន ប្តឹងពីឈ្មោះអ៊ាង សារឿន និង អ៊ាង សុវណ្ណ ដែលបានព្រួតគ្នាវាយប្តីខ្លួនបណ្តាលអោយស្លាប់កាលពីថ្ងៃទី១៦_១២_៩៤ វេលាម៉ោង៨ និង ៣០នាទី ។

-បានឃើញចម្លើយជនជាប់ចោទឈ្មោះអ៊ាង សុវណ្ណ បានឆ្លើយប្រហាក់ប្រហែលគ្នា នៅចំពោះមុខមន្ត្រីនគរបាល អយ្យការ ចៅក្រមស៊ើបអង្កេត និង នាពេលសវនាការនៃតុលាការក្រុងភ្នំពេញថា: ខ្លួនពុំបានវាយឈ្មោះអួនបណ្តាលអោយស្លាប់ទេ ខ្លួនគ្រាន់តែចូលទៅឃាត់ប្អូនខ្លួនឈ្មោះអ៊ាង សារឿនកុំអោយវាយប៉ុណ្ណោះ ប៉ុន្តែខ្លួនពុំបានឃើញអ៊ាង សារឿនវាយដោយផ្ទាល់ភ្នែកទេ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អម តុលាការក្រុងភ្នំពេញធ្វើសេចក្តីសន្និដ្ឋានចោទលើឈ្មោះអ៊ាង សុវណ្ណ , អ៊ាង សារឿន ពីបទធ្វើមនុស្សឃាតដោយចេតនាមានអាវុធប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី១៦_១២_៩៤ តាមបញ្ញត្តិមាត្រា៣២ច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ _ ៩_១៩៩២ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤១ "គ" ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៥របស់តុលាការក្រុងភ្នំពេញដែលបានសំរេច :

១_ផ្តន្ទាទោសឈ្មោះអ៊ាង សារឿនដាក់ពន្ធនាគារកំណត់១០ឆ្នាំគិតពីថ្ងៃចាប់ខ្លួន បានពីបទធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី១៦_១២_៩៤ តាមបញ្ញត្តិមាត្រា៣២ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-អោយអ៊ាង សារឿន សងទៅ ដើមបណ្ដឹងរដ្ឋប្ប វេណីចំនួន១០តម្លឹងមាស ។ ក្នុងករណីមិនសងត្រូវរឹបអូសទ្រព្យសម្បត្តិ និង ដាក់គុកបង្ខំលើរូបកាយតាមច្បាប់ស្ដីពីការដាក់គុកបង្ខំលើរូបរាងកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣-អោយឈ្មោះអ៊ាង សុវណ្ណរួចខ្លួនពីការចោទប្រកាន់ពីបទធ្វើមនុស្សឃាដដោយចេតនាមានអាវុធ ។

៤-អោយដោះលែងជាបន្ទាន់ឈ្មោះអ៊ាង សុវណ្ណភេទប្រុស អាយុ២៨ឆ្នាំ ។

៥-វត្ថុតាងមានដំបងឈើ ១ ត្រូវរឹបអូសនិងបំផ្លាញចោល ។

៦-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខអ៊ាង សុវណ្ណ កំបាំងមុខអ៊ាង - សារឿន សិទ្ធបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ២៤ "គ" ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៥ របស់អ្នកស្រី-មាស សារឿន ដែលប្ដឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ៤១ "គ" ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញលើសេចក្ដីសំរេចទាំងមូល ។

-បានឃើញសេចក្ដីសន្និដ្ឋាននាពេលសវនាការរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ ឈ្មោះអ៊ាងសារឿន មានពិរុទ្ធភាពគ្រប់គ្រាន់ តែឈ្មោះអ៊ាង សុវណ្ណពុំមានពិរុទ្ធភាពគ្រប់គ្រាន់ និងចម្លើយសាក្សីពុំមានភាពច្បាស់លាស់ទេ ។ ដូចនេះសូមតុលាការតម្កល់សេចក្ដីសំរេចរបស់តុលាការថ្នាក់ក្រោម និង សូមពិចារណាទៅតាមច្បាប់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៧៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ដែលបានសំរេច ៈ

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-៦-៩៥របស់ឈ្មោះមាស សារឿនទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៤១ "គ" ចុះថ្ងៃទី៣០-៦-៩៥ទុកជាបានការ លើកលែងតែចំណុចទី២ ,៣ និង ទី៤ត្រូវបដិសេធចោលហើយសំរេចជាថ្មីដូចខាងក្រោម ៈ

ក-ផ្តន្ទាទោសឈ្មោះអ៊ាង សុវណ្ណដាក់ពន្ធនាគារកំណត់១០ឆ្នាំគិតពីថ្ងៃសាលដីកាចូលជាស្ថាពរ តែទោសនេះត្រូវដក៦ ខែ ១១ថ្ងៃចេញ ដោយឈ្មោះនេះបានទទួលរងរួចហើយពីបទធ្វើមនុស្សឃាដដោយចេតនាមានអាវុធប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី១៦-១២-៩៤ តាមបញ្ញត្តិមាត្រា៣២ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ខ-អោយឈ្មោះអ៊ាង សារឿន និង អ៊ាង សុវណ្ណសងជម្ងឺចិត្តក្នុងម្នាក់ៗ ចំនួន១០តម្លឹងមាសអោយទៅ ដើមបណ្ដឹងរដ្ឋប្ប វេណីឈ្មោះមាស សារឿន ។ ក្នុងករណីជនល្មើសទាំងពីរនឹងរួសមិនព្រមសងសំណងជម្ងឺចិត្តនេះទេ ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុងដើម្បីធានាសំណង បើសងមិនគ្រប់ត្រូវដាក់គុកបង្ខំលើរូបកាយតាមច្បាប់ស្ដីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣-សាលដីកា នេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្ប-វេណីឈ្មោះ មាស សារឿន កំបាំងមុខជនជាប់ចោទឈ្មោះ អ៊ាង សុវណ្ណ អ៊ាង សារឿនសំរេចបើកផ្លូវប្តឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ២៥៩ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់អ្នកស្រីមាស សារឿន ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៧៣ ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៥របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៨របស់ឈ្មោះ អ៊ាង សារឿន "ជាម្ចាស់បណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាតបចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៨របស់អ្នកស្រីមាសសារឿន "ជាចុងបណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានស្តាប់អំណានសាវតាជាតិរបស់អ្នកស្រីមាស សារឿន "ជាចុង បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះ ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍.

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម តុលាការកំពូលថា :

១-បណ្តឹងសាទុក្ខរបស់ឈ្មោះ អ៊ាង សារឿន ស្ថិតក្នុងកំណត់ច្បាប់គប្បី លើកយកមករឿងនេះមកពិនិត្យពិចារណា ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៧៣ ចុះថ្ងៃទី០៣-១១-៩៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ អ៊ាង សារឿន " ជាម្ចាស់-បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា :តុលាការថ្នាក់ក្រោមសំរេចសេចក្តីអយុត្តិធម៌ កាលខ្ញុំវាយតំជនរងគ្រោះ គឺដើម្បី អោយជនរងគ្រោះសងការខូចខាតឡានរបស់ខ្ញុំ ពេលខ្ញុំពុំបានវាយជនរង-គ្រោះអោយស្លាប់ទេ សូមជួយរកយុត្តិធម៌អោយខ្ញុំផង ។

-បានស្តាប់អំណាសារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រីមាស សារឿន "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពារអ្នកស្រីឈឹម ស៊ីម៉េន ជាមេធាវីការពារអោយជនជាប់ចោទឈ្មោះ អ៊ាង សារឿន នៅពេលជំនុំជំរះថា : តុលាការថ្នាក់ក្រោមស៊ើបអង្កេតពុំគ្រប់ជ្រុងជ្រោយ សូមក្រុមប្រឹក្សាជំនុំជំរះបន្ធូរបន្ថយទោសដល់ជនជាប់ចោទឈ្មោះ អ៊ាង សារឿន និងបន្តលើកលែងទោសចំពោះជនជាប់ចោទឈ្មោះ អ៊ាង សុវណ្ណ ទៀតផង ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការរបស់តំណាងមហាអយ្យការអម

តុលាការកំពូលថា៖ សូមតម្កល់សេចក្ដីសន្និដ្ឋានទុកនៅដដែល ។

- ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយដោះសាររបស់ជនជាប់ចោទ សារណាតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និង សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៤៥៨ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ឈ្មោះ - អ៊ាង សារឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

-យល់ឃើញថា ការលើកឡើងរបស់មេធាវីការពារជនជាប់ចោទក្នុងសារណារបស់ខ្លួនថាការដែលជនរងគ្រោះស្លាប់ ពុំមែនជាអំពើរបស់ឈ្មោះអ៊ាង សារឿន ទេគឺបណ្ដាលមកពីការវាយរបស់បងប្អូនជនរងគ្រោះតែម្ដង ដែលក្នុងគោលបំណងវាយអ៊ាង សារឿន តែដោយពេលនោះងងឹត ហើយជនរងគ្រោះ នៅពីលើអ៊ាង សារឿន ក៏នាំគ្នាវាយស្មានថា អ៊ាង សារឿននៅពីលើនោះគឺជាការពុំត្រឹមត្រូវឡើយពីព្រោះថានៅកន្លែងកើតហេតុនោះ ពេលកំពង់វាយមានសាក្សីឃើញច្បាស់បញ្ជាក់ថា ឈ្មោះអ៊ាង សារឿនកាន់ដំបង ២កំណាត់ និង ឈ្មោះអ៊ាង សុវណ្ណកាន់ដំបង ៤ ព្រួតវាយទៅលើឈ្មោះនួន គឹម សេងបណ្ដាលអោយស្លាប់ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-យល់ឃើញថា ការលើកឡើងរបស់មេធាវីជនជាប់ចោទនាសវនាការនេះថាបទល្មើសនេះមិនមែនជាបទមនុស្សឃាតដោយចេតនាទេ គឺជាបទល្មើសបង្ករបួសស្នាមព្រោះថាជនរងគ្រោះមិនស្លាប់នៅកន្លែងកើតហេតុ នោះជាការមិនត្រឹមត្រូវឡើយ តាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលពុំបានកំណត់ថាចាំបាច់ទាល់តែស្លាប់នៅកន្លែងកើតហេតុនោះទេ ។

-យល់ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៧៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់សាលា-ឧទ្ធរណ៍ដែលបាន សំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី

ប៉ុន្តែចាត់ទុកជាចំពោះមុខ ៖

១-ទទួលបណ្ដឹងសាទុក្ខលេខ៤៥៨ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ឈ្មោះអ៊ាង សារឿន

ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២_តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៧៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៥របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣_សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៨ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាផ្នែកព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៥០

ចុះថ្ងៃទី០១ខែតុលាឆ្នាំ១៩៩៨

<u>សាលដីកា</u>

លេខ : ១៧

ចុះថ្ងៃទី១៩ខែឧសភាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ១៩៩៩

ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ឃឹម ស៊ីផល ចៅក្រមរបាយការណ៍

៣- លោក ប្រាក់ គឹមសាន ចៅក្រម

៤- លោក សោម សិរីវឌ្ឍ ចៅក្រម

៥- លោក យស់ សួខឿន ចៅក្រម

ក្រឡាបញ្ជី

លោក ទេព ចាន់ថា

តំណាងមហាអយ្យការ

លោក ចែន សាវឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ១៤៦ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ៥០ ចុះថ្ងៃទី ០១ ខែ តុលាឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

<u>ពីបទ</u> : រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី០៩-០៥-៩៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រាទី ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០-០៩-៩២ ។

- ជនជាប់ចោទឈ្មោះ តាំង ឌីណ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៤៧ ឆ្នាំ ជាតិខ្មែរ មុខរបរបោកអ៊ុត ទីលំនៅ ផ្ទះលេខ ៥៩អឺ២ ផ្លូវលេខ ១៣០ សង្កាត់ផ្សារចាស់ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ តាំង ហ៊ុន "ស" ម្តាយឈ្មោះ ហុង គី "រ" ប្តីឈ្មោះ អៀ ម៉េងឃាង មានកូន ០៤នាក់ ទោសពីមុនគ្មាន ។

មេធាវី ឬ អ្នកការពារ គ្មាន ។

- ដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះឈ្មោះ លី អ៊ុយ "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៥១ ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅផ្ទះលេខ ១៨១អឺ១ ផ្លូវស៊ីសុវត្ថិ